ធ ៧-០២- ៤៨ ប្រ.ក

# ប្រកាស
# ស្តីពី
# អនុបាតសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/ ៨៥ ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- បានឃើញប្រកាសលេខធ ៧០០-០៦ ប្រ.ក ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- យោងតាមការឯកភាពរបស់អង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជានៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០២ ។

## សំរេច

**ប្រការ ១.-** គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណត្រូវរក្សាសាច់ប្រាក់ងាយស្រួលអោយបានគ្រប់គ្រាន់ជាអចិន្ត្រៃយ៍យ៉ាងហោចណាស់ស្មើនឹងមួយរយភាគរយ (១០០%) ។

**ប្រការ ២.-** អនុបាតសាច់ប្រាក់ងាយស្រួលនេះត្រូវបានគណនាដូចខាងក្រោម :

- **ភាគយក :** សាច់ប្រាក់ក្នុងដៃ + ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា + ប្រាក់បញ្ញើនៅធនាគារផ្សេងៗ - ប្រាក់ខ្ចីពីធនាគារជាតិនៃកម្ពុជា និងធនាគារផ្សេងៗ (សាច់ប្រាក់ងាយស្រួលសុទ្ធ) + ឥណទានដែលឥណប្រតិទាននៅសល់តិចជាងមួយខែ ។
- **ភាគបែង :** ម្ភៃប្រាំភាគរយ (២៥%) នៃប្រាក់សន្សំដោយស្ម័គ្រចិត្តមិនរួមបញ្ចូលប្រាក់សន្សំកាតព្វកិច្ច ។

**ប្រការ ៣.-** គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវផ្តល់ឯកសារពីការគណនាអនុបាតសាច់ប្រាក់ងាយស្រួលប្រចាំខែរបស់ខ្លួនតាមគំរូរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៤.-** គ្រឹះស្ថានណាមិនគោរពតាមបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៥.-** រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦.-** អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៧.-** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២

**ទេសាភិបាល**

**<u>កន្លែងទទួល</u>**

- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**<u>ចម្លងជូន</u>**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

B 7-02-48 Pror Kor Unofficial translation

# PRAKAS
# ON
# LIQUIDITY RATIO APPLICABLE
# TO LICENSED MICROFINANCE INSTITUTIONS

-----------------------------

The Governor of the National Bank of Cambodia

- With reference to the Constitution of the Kingdom of Cambodia,

- With reference to the Royal Kram NS/RKM/ 0196/27 of January 26, 1996 promulgating the Law on the Organization and Functioning of the National Bank of Cambodia,

- With reference to the Royal Kram NS/RKM/ 1199/13 of November 18,1999 promulgating the Law on Banking and Financial Institutions,

- With reference to the Royal Decree Chor Sor/RKT/0398/85 of March 10, 1998 on the appointment of His Excellency Chea Chanto as Governor General of the National Bank of Cambodia,

- With reference to the PRAKAS No. B 700-06 Pror Kor of January 11, 2000 on Licensing of Micro-finance Institution,

- Pursuant to the agreement of the leader meeting of the National Bank of Cambodia on January 23, 2002.

## Decides

**Article 1** Licensed Microfinance Institutions shall at all times maintain a liquidity ratio of at least 100%.

**Article 2** The liquidity ratio will be calculated as follows:

- *numerator*: cash on hand, plus deposits with the National Bank of Cambodia. plus deposits with banks, minus the amount owed to the National Bank of Cambodia and banks ( net liquidity), plus the portion of loans outstanding maturing in less than one month
- *denominator*: 25% of voluntary savings, excluding compulsory savings.

**Article 3** Licensed Microfinance Institutions shall file monthly calculations of their liquidity ratio in accordance with the reporting format prepared by the National Bank of Cambodia.

**Article 4** Violations to the provisions of this Prakas may give rise to disciplinary sanctions as set forth in Article 52 of the *law on Banking and Financial Institutions.*

**Article 5** All provisions contrary to this Prakas are hereby repealed.

**Article 6** The General Direction, the General Secretariat, the General inspection, the General Cashier and all departments of the National Bank of Cambodia, and all Micro Financial Institutions under of the National Bank of Cambodia supervisory authority shall strictly implement this Prakas.

**Article 7** This Prakas shall have effect from the signing date.

Phnom Penh, February 25, 2002

Governor
Signed and sealed: CHEA CHANTO

cc: -The member of the Board of directors
-The parties concerned as stated in Article 6
-File
-CM " for info "
- Administration
-Department of CM
" for publication in the National Gazette "